00198498

C22/I/54

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

អង្គបុរេជំនុំជម្រះ

ចំពោះមុខៈ

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទៈ ០៣ កក្កដា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / JULY / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

## សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលបានសម្រេចផ្ទាល់មាត់នៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៨ អំពីសំណើសុំលើកអំណះអំណាងនៅចំពោះមុខតុលាការដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / JULY / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
Silke STUDZINSKY

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G.KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C. * C.E.T.C.

១- នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបន្តសវនាការបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

២- ក្នុងអំឡុងពេលសវនាការ សហមេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ អាចលើកអំណះអំណាងដោយផ្ទាល់នៅចំពោះមុខតុលាការ។ សហមេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានជម្រាបជូនអង្គបុរេជំនុំជម្រះថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះបានបោះបង់មេធាវីរបស់ខ្លួនហើយ។

៣- អង្គបុរេជំនុំជម្រះយល់ឃើញថា មិនអាចអនុញ្ញាតអោយដើមបណ្តឹងរដ្ឋប្បវេណីលើកអំណះអំណាងដោយផ្ទាល់នៅចំពោះមុខតុលាការបានទេ។ បទប្បញ្ញត្តិក្នុងវិធានផ្ទៃក្នុងបានបញ្ជាក់យ៉ាងច្បាស់លាស់រួចហើយ។ វិធានផ្ទៃក្នុងបានបញ្ញត្តយ៉ាងជាក់លាក់ចំពោះដំណើរការនីតិវិធីក្នុងដំណាក់កាលមុនអង្គសេចក្តីទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គេ។វិធាន ៧៧-១០ នៃវិធានផ្ទៃក្នុងចែងថា មានតែមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទើបមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយសង្ខេបក្នុងបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះបាន។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

*បដិសេធសំណើសុំលើកអំណះអំណាងនៅចំពោះមុខតុលាការដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី។*

**សេចក្តីសម្រេចផ្ទាល់មាត់បានធ្វើឡើងនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨**

ភ្នំពេញ, ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER / CHAMBRE PRÉLIMINAIRE — E.C.C.C.

**ប្រាក់ គឹមសាន**

- **មានភ្ជាប់នូវយោបល់ជំទាស់របស់ចៅក្រម Rowan Downing ។**

# យោបល់ជំទាស់របស់ចៅក្រម Rowan Downing

១- ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានស្នើសុំលើកអំណះអំណាងដោយផ្ទាល់នៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី**។ វាហាក់ដូចជាមានភាពផ្ទុយគ្នារវាងវិធាន ២៣ នៃវិធានផ្ទៃក្នុង ដែលផ្តល់សិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមក្នុងសវនាការ និងវិធាន៧៧-១០ នៃវិធានផ្ទៃក្នុង ដែលមានការកម្រិតលើការលើកឡើងនូវអំណះអំណាងនៅចំពោះមុខអង្គបុរេជំនុំជម្រះ របស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅអោយ "មេធាវីដើមបណ្តឹងរដ្ឋប្បវេណី" ទៅវិញ។

២- វាបង្ហាញយ៉ាងច្បាស់ថា វិធាន ២៣ ផ្តល់សិទ្ធិចូលរួមជាទូទៅ ដែលមានលក្ខណៈសមស្របក្នុងរឿងបណ្តឹងឧទ្ធរណ៍ និងពាក្យស្នើសុំជាក់លាក់នេះនៅអង្គបុរេជំនុំជម្រះដូចដែលមានចែងក្នុងវិធាន៧៧-១០ នៃវិធានផ្ទៃក្នុង។

៣- យើងបានដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់មេធាវីរបស់ខ្លួន ដូច្នេះ បណ្តឹងរដ្ឋប្បវេណីនេះលែងមានអ្នកតំណាងនៅចំពោះមុខអង្គបុរេជំនុំជម្រះទៀតហើយ។ នៅក្នុងរឿងក្តីជាក់លាក់នេះ ខ្ញុំនឹងរៀបចំខ្លួនក្នុងការផ្តល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះអាចចូលរួម និងអាចលើកអំណះអំណាងអំពីបញ្ហាយុត្តាធិការនៅចំពោះមុខអង្គជំនុំជម្រះបាន ទោះបីជាមានការដាក់កម្រិតដូចមានកំណត់នៅក្នុងវិធានផ្ទៃក្នុង៧៧-១០ យ៉ាងណាក៏ដោយ។ ខ្ញុំសម្រេចធ្វើបែបនេះ ដោយឈរលើមូលដ្ឋានថា វាអាចផលប៉ះពាល់មួយនៃសេចក្តីសម្រេចនៅក្នុងបញ្ហានេះ ដែលវានឹងធ្វើអោយដើមបណ្តឹងរដ្ឋប្បវេណីនេះបានបង់សិទ្ធិធ្វើការទាមទារប្រឆាំងនឹងជនត្រូវចោទ ដូចមានចែងក្នុងវិធាន ២៣-១(ខ) នៃវិធានផ្ទៃក្នុង។

៤- ហេតុដូច្នេះ តាមយោបល់របស់ខ្ញុំ បើអនុលោមតាមគោលការណ៍ជាមូលដ្ឋាននៃវិធាន ២១-១(ក) គឺវាមិនមានយុត្តិធម៌ឡើយ ដែលមិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឡើងលើកអំណះអំណាងនៅចំពោះមុខតុលាការបានទេនោះ។

**សេចក្តីសម្រេចផ្ទាល់មាត់បានធ្វើឡើងនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨**

ភ្នំពេញ, ថ្ងៃ០៣ ខែកក្កដា ឆ្នាំ២០០៨

**ចៅក្រម** Rowan Downing

Rowan Downing

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. C.E.T.C.